# (៤២)

# កិច្ចព្រមព្រៀងស្តីពី
# ការផ្តល់សេវាកម្មបើកប្រាក់បៀវត្សជូនបុគ្គលិក
# មន្ត្រីរាជការតាមរយៈប្រព័ន្ធធនាគារកាណាឌីយ៉ា ក.អ

ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង
## ស្តីពីការផ្តល់សេវាកម្មបើកប្រាក់បៀវត្សជូនបុគ្គលិកមន្ត្រីរាជការ
## តាមរយៈប្រព័ន្ធធនាគារកាណាឌីយ៉ា ក.អ

យោង ៖ អនុស្សរណៈនៃការយោគយល់គ្នាស្តីពី ការប្រើប្រាស់សេវាកម្មរបស់ធនាគារកាណាឌីយ៉ា ក.អ សម្រាប់ប្រតិបត្តិការ គណនីប្រាក់បៀវត្សមន្ត្រីរាជការ អនុវត្តជាជំហានៗនៅទូទាំងប្រទេស រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារកាណាឌីយ៉ា ក.អ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣" ។

... រវាង

ភាគី "ក"

ឈ្មោះក្រសួង : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាសយដ្ឋាន : លេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ : (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩

ទូរសារ : (៨៥៥) ២៣ ២១៧ ៣២០

តំណាងដោយ : ឯកឧត្តម គុយ ម៉ារិនឌី

ភាគី "ខ"

ឈ្មោះធនាគារ : ធនាគារកាណាឌីយ៉ា ក.អ

អាសយដ្ឋាន : អគារលេខ៣១៥ ផ្លូវព្រះអង្គឌួង (កែងមហាវិថីព្រះមុនីវង្ស) រាជធានីភ្នំពេញ

ទូរស័ព្ទ : (៨៥៥) ២៣ ៨៦៨ ២២២

ទូរសារ : (៨៥៥) ២៣ ២២៣ ៦១១

តំណាងដោយ : Mr LOR CHEE LENG

ភាគីទាំងពីរបានឯកភាពអំពីគោលបំណង និងលក្ខខណ្ឌអនុវត្តកិច្ចព្រមព្រៀង ដូចខាងក្រោម ៖

ប្រការ១៖ ភាគី "ក" នឹងបញ្ជូនបញ្ជីឈ្មោះបុគ្គលិកមន្ត្រីរាជការដែលត្រូវបើកគណនីមក ភាគី "ខ" ដោយភ្ជាប់មកជាមួយអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែន ឬ អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល ឬ ប័ណ្ណសំគាល់មន្ត្រីរាជការដែលមានសុពលភាព ដើម្បីឲ្យធនាគារធ្វើការរៀបចំបើកគណនីជូន។

ប្រការ២៖ រាល់ការផ្ទេរប្រាក់បៀវត្សចូលក្នុងគណនីរបស់បុគ្គលិកមន្ត្រីរាជការ គឺត្រូវធ្វើទៅតាមបញ្ជីឈ្មោះដែលភាគី "ក" បានកំណត់។

ប្រការ៣៖ ក្នុងករណីមានការកែប្រែណាមួយទាក់ទងនឹងស្ថានភាពគ្រួសាររបស់បុគ្គលិកមន្ត្រីរាជការ (ដូចជាបុគ្គលិកមន្ត្រីរាជការចូលនិវត្តន៍ មរណភាព ឬសុំលាឈប់ ។ល។) ភាគី "ក" នឹងជូនដំណឹងមកភាគី "ខ" ជាលាយលក្ខណ៍អក្សរ ។

ប្រការ៤៖ បន្ទុកចំណាយលើការផ្តល់សេវាជាមួយភាគី "ខ" បុគ្គលិកមន្ត្រីរាជការ[illegible] ដូចមាន ចែងក្នុងឧបសម្ព័ន្ធភ្ជាប់មកជាមួយ។

ប្រការ៥៖ កិច្ចព្រមព្រៀងនេះមានសុពលភាពរហូតដល់ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ និងអនុលោមទៅតាមអនុស្សរណៈ យោគយល់គ្នា ដូចមានយោងខាងលើ។

ប្រការ៦៖ ប្រសិនបើភាគី "ក" ឬបុគ្គលិកមន្ត្រីរាជការ នៅតែចង់បន្តការប្រើប្រាស់សេវាកម្មរបស់ធនាគារកាណាឌីយ៉ា ក្រោយពេលផុតសុពលភាពដូចមានចែងក្នុងប្រការ៥ ខាងលើ ភាគី "ក" និងបុគ្គលិកមន្ត្រីរាជការត្រូវ អនុវត្តតាមគោលការណ៍ របស់ភាគី "ខ"។

ប្រការ៧៖ ការធ្វើវិសោធនកម្ម ឬខ្លឹមសារបំពេញបន្ថែមនៃកិច្ចព្រមព្រៀងនេះ នឹងត្រូវធ្វើឡើងជាលាយលក្ខណ៍ អក្សរហើយមានលក្ខណៈ ជាកិច្ចព្រមព្រៀងបន្ថែម និងត្រូវចុះហត្ថលេខាដោយភាគីទាំងសងខាង។

ប្រការ៨៖ កិច្ចព្រមព្រៀងនេះ ត្រូវបានធ្វើឡើងជាបួន(៤)ច្បាប់ដើម ជាភាសាខ្មែរ មានតម្លៃស្មើគ្នា រក្សាទុកនៅភាគី ទាំងពីរ ម្នាក់ពីរ(២) ច្បាប់ដើម និងមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ប្រការ៩៖ កិច្ចព្រមព្រៀងនេះ ត្រូវបានគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ -៚

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែសីហា ឆ្នាំ ២០១៤

| តំណាងភាគី "ក" | តំណាងភាគី "ខ" |
|---|---|
| ឈ្មោះ: ឯកឧត្តម គុយ ម៉ារិនឌី | ឈ្មោះ: LOR CHEE LENG |
| មុខងារ: អនុរដ្ឋលេខាធិការ | មុខងារ: នាយកប្រតិបត្តិ |
| សាក្សីភាគី "ក" | សាក្សីភាគី "ខ" |
| ឈ្មោះ: ឯកឧត្តម ឡោ ស៊ើ | ឈ្មោះ: គាន់ សំណាង |
| មុខងារ: អគ្គលេខាធិការ | មុខងារ: នាយកផ្នែកប្រតិបត្តិការកណ្តាល |

CANADIA BANK PLC
ធនាគារ កាណាឌីយ៉ា ភ.ក
PHNOM PENH, CAMBODIA

# ឧបសម្ព័ន្ធ

## សេវាបើកប្រាក់បៀវត្សរ៍សម្រាប់មន្ត្រីរាជការ

## តាមរយៈធនាគារកាណាឌីយ៉ា ក.អ

សេវាបើកប្រាក់បៀវត្សរ៍សម្រាប់មន្ត្រីរាជការរបស់ធនាគារ កាណាឌីយ៉ាគឺជាសេវាកម្មសម្រាប់ប្រតិបត្តិការគណនីប្រាក់បៀវត្សរ៍មន្ត្រីរាជការ ផ្តល់ជូនក្រសួង មន្ទីរ ឬស្ថាប័នរដ្ឋនានា យោងតាមអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារ កាណាឌីយ៉ា ក.អ ចុះថ្ងៃទី 27 ខែវិច្ឆិកា ឆ្នាំ2013 ។

I. លក្ខណៈពិសេស និងអត្ថប្រយោជន៍៖

1. មិនតម្រូវឲ្យមានប្រាក់តម្កល់ពេលបើកគណនី ។
2. អត្រាការប្រាក់1.25% ប្រចាំឆ្នាំ ។
3. អាចស្នើសុំធ្វើបុរេប្រទានបានតាមរយៈសេវាកម្មរ៉េឌីខេស (Ready Cash - Overdraft Facility) និងឥណទានផ្ទាល់ខ្លួនសម្រាប់មន្ត្រីរាជការស៊ីវិល (Personal Loan for Civil Servant)។[1]
4. ទទួលបានកាតអេធីអឹម (ATM) ដោយឥតគិតកម្រៃសេវាប្រចាំខែនិងប្រចាំឆ្នាំ៖
   - 4.1. ករណីខូចខាត (សូមភ្ជាប់កាតខូចមកជាមួយ)ធនាគារនឹងធ្វើកាតថ្មីជូនវិញ ដោយឥតគិតកម្រៃសេវា(៣ដង ក្នុង១ឆ្នាំ)។ចាប់ពីលើកទី៤ នឹងគិតតាមតម្លៃ កំណត់ដោយធនាគារ ។
   - 4.2. ករណីបាត់កាត ធនាគារនឹងផ្តល់ជូនកាតថ្មីតាមតម្លៃកំណត់ដោយធនាគារ ។
5. អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាកម្មអេធីអឹម (ATM)៖[2]
   - 5.1. អាចផ្ទេរប្រាក់ទៅគណនីផ្សេងទៀតរបស់ធនាគារកាណាឌីយ៉ា ដោយឥតកម្រៃសេវា ។
   - 5.2. អាចដកសាច់ប្រាក់ និងប្តូរប្រាក់ជារូបិយប័ណ្ណរៀល ឬ ដុល្លារអាមេរិក (ទាំងគណនីរៀល និងគណនីដុល្លារអាមេរិក)។
   - 5.3. អាចបង់វិក្កយបត្ររដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងអគ្គិសនីកម្ពុជា ក្រុងភ្នំពេញ និងខេត្តកណ្តាល(តាខ្មៅ) ដោយគិតកម្រៃ 1,000រៀល ក្នុង1ដង។
   - 5.4. អាចពិនិត្យមើលសមតុល្យទឹកប្រាក់ ពិនិត្យមើលរបាយការណ៍សង្ខេប និងបោះពុម្ពវិក្កយបត្រ ដោយឥតគិតកម្រៃសេវា។
   - 5.5. សេវាកម្មអេធីអឹម (ATM) បម្រើជូនអតិថិជន 24ម៉ោង ក្នុងមួយថ្ងៃ និង 7ថ្ងៃ ក្នុងមួយសប្តាហ៍។
6. ចុះឈ្មោះប្រើប្រាស់សេវាកម្មធនាគារតាមប្រព័ន្ធអ៊ីនធឺណិត និងទូរស័ព្ទដៃដោយឥតគិតកម្រៃសេវា។
7. តំឡើងជូនម៉ាស៊ីនអេធីអឹម (ATM) នៅតាមបណ្តាក្រសួង មន្ទីរ ឬស្ថាប័ន ។[3]

---

[1] ផ្តល់ជូនចំពោះមន្ត្រីរាជការស៊ីវិលតែប៉ុណ្ណោះ ។

[2] ចំនួនទឹកប្រាក់កំណត់ក្នុងមួយប្រតិបត្តិការនឹងកើនឡើងដល់ 700,000រៀលនិងចំពោះទឹកប្រាក់កំណត់ប្រចាំថ្ងៃនឹងកើនឡើងដល់ 4,000,000 ។ ការតំឡើងនេះ នឹងអនុវត្តនៅគ្រប់ អេធីអឹម ចាប់ពីខែ កញ្ញា 2014 នេះតទៅ ។

[3] ការតំឡើងម៉ាស៊ីនអេធីអឹមអាស្រ័យលើចំនួនមន្ត្រីរាជការនៃក្រសួងពាក់ព័ន្ធនិងទីតាំងដែលត្រូវតំឡើង។

8. អាចដកប្រាក់តាមបញ្ជរបេឡា គ្រប់សាខាធនាគារ កាណាឌីយ៉ា ដោយគិតកម្រៃសេវា ក្នុងករណីផ្ទេរ ឬដកឆ្លងសាខា មួយថ្ងៃដកបានចំនួនអតិបរិមាស្មើនឹងចំនួនប្រាក់បៀវត្សប្រចាំខែ (លើកលែងសាខានៅទីក្រុងភ្នំពេញ និងសាខាតាខ្មៅ)។

9. មន្ត្រីរាជការដែលបើកគណនីប្រាក់បៀវត្សរ៍នៅធនាគារកាណាឌីយ៉ា និងមានឱកាសទទួលបានការបញ្ចុះតម្លៃពិសេសលើការទិញអចលនទ្រព្យដែលអភិវឌ្ឍន៍ដោយ កាណាឌីយ៉ាគ្រុប ឬគម្រោងអចលនទ្រព្យដែលផ្តល់ហិរញ្ញប្បទានដោយធនាគារកាណាឌីយ៉ា ឬការជាវសេវាកម្មពីសណ្ឋាគារដារ៉ាអ៊ែរផត (Dara Airport Hotel) នៅរាជធានីភ្នំពេញ, សណ្ឋាគារឯករាជ្យ (Independence Hotel) នៅក្រុងព្រះសីហនុ, ក្លឹបហាត់ប្រាណនៅវិមានកុលាប, ក្លឹបហាត់ប្រាណ និងកីឡាវាយកូនហ្គោល អេលីត (Elite Golf Club), សេវាកម្មផ្សេងៗរបស់វិមានមេគង្គ, ភូមិវប្បធម៌, មជ្ឈមណ្ឌលមហាសន្និបាត និងពិព័រណ៍កោះពេជ្រ, មជ្ឈមណ្ឌលវប្បធម៌វិមានកែវចរណៃ (ចេនឡា) និងតាមបណ្តាហាង ឬក្រុមហ៊ុននានា ដែលជាដៃគូពាណិជ្ជកម្មរបស់ធនាគារកាណាឌីយ៉ា ។ [១]

៩.១ ការផ្តល់ជូនពិសេសលើឥណទានទិញផ្ទះ:

9.1.1 អត្រាការប្រាក់ពិសេស ។

9.1.2 អាចស្នើឥណទានរហូត៨០%នៃទ្រព្យដាក់បញ្ចាំ។

9.1.3 អាចស្នើឥណទានរហូតដល់ ២០ឆ្នាំ ។

9.1.4 ទទួលបានការបញ្ចុះតំលៃបន្ថែម ១% រាល់ការទិញផ្ទះពីគំរោងរបស់ក្រុមហ៊ុន OCIC ។

9.2 ការជាវសេវាកម្មពីមជ្ឈមណ្ឌលមហាសន្និបាតពិព័រណ៍កោះពេជ្រ និងមជ្ឈមណ្ឌលវប្បធម៌វិមានកែវចរណៃ (ចេនឡា)

9.2.1 បញ្ចុះតំលៃ ១0% លើតំលៃតុចំពោះរាល់ការជាវសេវាកម្មក្នុងអំឡុងពេល ពីខែមិថុនារហូតដល់ខែតុលា ។

9.2.2 បញ្ចុះតំលៃ ៥% លើតំលៃតុចំពោះរាល់ការជាវសេវាកម្មក្នុងអំឡុងពេល ពីខែវិច្ឆិការហូតដល់ខែឧសភា ។

9.2.3 លក្ខខណ្ឌពិសេសតាមចំនុច (9.2.1) និង (9.2.2) មានសុពលភាពចំពោះតែអតិថិជន និង បុគ្គលិកគ្រួសារ តែប៉ុណ្ណោះ ។

---

១ លក្ខខណ្ឌ និងបទបញ្ញត្តិនានាត្រូវបានអនុវត្តន៍ ។ ធនាគាររក្សាសិទ្ធក្នុងការកែប្រែលក្ខខណ្ឌនិងបទបញ្ញត្តិដែលបាន កំណត់។

II. ភាពងាយស្រួលនៃការប្រើប្រាស់សេវាបើកប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការ

1. មន្ត្រីធនាគារកាណាឌីយ៉ានឹងបើកគណនីប្រាក់បៀវត្សជូនមន្ត្រីរាជការដល់ទីកន្លែងនៃក្រសួង មន្ទីរ ឬស្ថាប័នសាមី ។
2. មានភាពងាយស្រួលក្នុងការដកសាច់ប្រាក់ជាមួយម៉ាស៊ីនអេធីអឹម (ATM) ជាង100 កន្លែងនៅទូទាំងប្រទេស ដែលរួមមានទីតាំង នៅតាមបណ្តាសាខា ធនាគារ កាណាឌីយ៉ា ក្រសួងនានានៅទីក្រុងភ្នំពេញ មជ្ឈមណ្ឌលពាណិជ្ជកម្មធំៗ អាកាសយានដ្ឋានអន្តរជាតិ និងស្ថានីយ៍ប្រេងឥន្ធនៈ ។ល។
3. មានភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការធនាគារជាមួយសាខាកាណាឌីយ៉ា ដែលមានចំនួន ៥០សាខាទូទាំងប្រទេស (រាជធានី ភ្នំពេញមានចំនួន 22សាខា)។[១]
4. មានភាពងាយស្រួល និងសុវត្ថិភាពចំពោះមន្ត្រីរាជការក្នុងការទុកដាក់សាច់ប្រាក់ និង ទទួលបានសេវាកម្មឆាប់រហ័ស ទំនើប និងទាន់សម័យ ។
5. មានភាពងាយស្រួលនិងសុវត្ថិភាពក្នុងការគ្រប់គ្រងសាច់ប្រាក់ជូន ក្រសួង មន្ទីរ ឬស្ថាប័ន សាមីៗ

III. <u>ឯកសារចាំបាច់ក្នុងការបើកគណនី</u>

ការបើកគណនីប្រាក់បៀវត្ស ក្រសួង មន្ទីរ ឬស្ថាប័នសាមីត្រូវបញ្ជូនបញ្ជីឈ្មោះផ្លូវការដល់មន្ត្រីធនាគារកាណាឌីយ៉ា ហើយមន្ត្រីរាជការត្រូវភ្ជាប់មកនូវឯកសារមួយក្នុងចំណោមឯកសារខាងក្រោមដែលមានសុពលភាព៖

- អត្តសញ្ញាណប័ណ្ណ ឬ
- លិខិតឆ្លងដែន ឬ
- អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល ឬ
- ប័ណ្ណសម្គាល់មន្ត្រីរាជការ។

---

១នៅត្រឹមចុងឆ្នាំ 2014 នេះ: ចំនួនសាខាធនាគារ កាណាឌីយ៉ា នឹងកើនឡើងដល់ 55 សាខា ទូទាំងប្រទេស (23 សាខានៅរាជធានីភ្នំពេញ)។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ទម្រង់ ពបវ ០១
Form TOS 01

**សម្រាប់មន្ត្រីពន្ធដារ For Tax Official**

ថ្ងៃទី [ ] DD ខែ [ ] MM ឆ្នាំ [ ] YY

លេខចូល Nº ....................

ហត្ថលេខា
Signature

ឈ្មោះមន្ត្រីពន្ធដារ ....................
Tax official Name

# លិខិតប្រកាសពន្ធលើប្រាក់បៀវត្ស
# Return for Tax on Salary

(មាត្រា ៥៣ នៃច្បាប់ស្តីពីសារពើពន្ធ)
(Article 53 of the Law on Taxation)

| 01 | ការិយបរិច្ឆេទសារពើពន្ធសម្រាប់លិខិតប្រកាសនេះ Period covered by this return | |
|---|---|---|
| | ពីថ្ងៃទី......ខែ........ឆ្នាំ.......... From (DD) Month (MM) Year (YYYY) | ដល់ថ្ងៃទី......ខែ........ឆ្នាំ.......... From (DD) Month (MM) Year (YYYY) |

| 02 | លេខអត្តសញ្ញាណកម្មសារពើពន្ធ TIN |
|---|---|
| | [ ][ ][ ][ ][ ][ ][ ][ ][ ] |

03

ឈ្មោះសហគ្រាស Name of Enterprise: ..............................................................

សកម្មភាពអាជីវកម្ម Business Activities: ..............................................................

អាសយដ្ឋាន Address: No................ ផ្លូវ Street.............................. ក្រុម Group.............. ភូមិ Village ....................

ឃុំ/សង្កាត់ Sangkat.................... ក្រុង/ស្រុក/ខណ្ឌ District .................... ខេត្ត/រាជធានី Municipality ....................

ទូរស័ព្ទ/ទូរសារ Fax/Phone .................... សារអេឡិចត្រូនិក E-mail ....................

## I. ពន្ធលើប្រាក់បៀវត្សចំពោះនិយោជិតនិវាសជន Tax on Salary on Resident Employees :

| 04 | ចំនួននិយោជិត No. of Employee | ប្រាក់បៀវត្សត្រូវបើក Salary to be Paid | សហព័ទ្ធ Spouse | ចំនួនកូនក្នុងបន្ទុក No. of M Children | មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស Tax on Salary Calculation Base | អត្រាពន្ធ Tax Rate | ពន្ធលើប្រាក់បៀវត្ស Tax on Salary |
|---|---|---|---|---|---|---|---|
| | A | B | C | D | E = B – [(C + D) x 75,000] | F | G |
| 1 | .......... | .......... | .......... | .......... | .......... | 0% | .......... |
| 2 | .......... | .......... | .......... | .......... | .......... | 5% | .......... |
| 3 | .......... | .......... | .......... | .......... | .......... | 10% | .......... |
| 4 | .......... | .......... | .......... | .......... | .......... | 15% | .......... |
| 5 | .......... | .......... | .......... | .......... | .......... | 20% | .......... |
| សរុប Total | .......... | .......... | .......... | .......... | .......... | | .......... |

## II. ពន្ធលើប្រាក់បៀវត្សចំពោះនិយោជិតអនិវាសជន Tax on Salary on Non-Resident Employees :

| 05 | ចំនួននិយោជិត No. of Employee | ប្រាក់បៀវត្សត្រូវបើក Salary to be Paid | | | | អត្រាពន្ធ Tax Rate | ពន្ធលើប្រាក់បៀវត្ស Tax on Salary |
|---|---|---|---|---|---|---|---|
| | A | B | | | | C | D = B x C |
| | .......... | .......... | | | | 20% | .......... |

## III. ពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម Tax on Salary on Fringe Benefit :

| 06 | ចំនួននិយោជិត No. of Employee | ចំនួនប្រាក់អត្ថប្រយោជន៍បន្ថែម Fringe Benefit Amount | | | | អត្រាពន្ធ Tax Rate | ពន្ធលើប្រាក់បៀវត្ស Tax on Salary |
|---|---|---|---|---|---|---|---|
| | A | B | | | | C | D = B x C |
| | .......... | .......... | | | | 20% | .......... |

| 07 | សរុបប្រាក់ពន្ធត្រូវបង់ Total Tax Due | .......... |
|---|---|---|

យើងខ្ញុំបានពិនិត្យគ្រប់ចំណុចទាំងអស់នៅលើលិខិតប្រកាសនេះ និងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយ ។ យើងខ្ញុំមានសក្ខីប័ត្របញ្ជាក់ច្បាស់លាស់ ត្រឹមត្រូវ ពេញលេញ ដែលធានាបានថា ព័ត៌មានទាំងអស់នៅលើលិខិតប្រកាសនេះពិតជាត្រឹមត្រូវប្រាកដមែន ហើយគ្មានប្រតិបត្តិការណាមួយមិនបានប្រកាសនោះទេ ។ យើងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ទាំងឡាយជាធរមាន ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ ។ We have examined all items on this return and the annexes attached here with. We have clear, correct, and full supporting documents to ensure that all information on this return is true and accurate and there is no business operation undeclared. We are fully responsible due to the existing Laws for any falsified information.

ធ្វើនៅ.................... ថ្ងៃទី [ ] DD ខែ [ ] MM ឆ្នាំ [ ] YYYY
Filed in

នាយក/អ្នកគ្រប់គ្រង/ម្ចាស់សហគ្រាស
Director/Manager/Owner of Enterprise
(ហត្ថលេខា និងត្រា Signature & Seal)

**សម្រាប់មន្ត្រីពន្ធដារ For Tax Official**

របៀបបង់នៃការបង់ប្រាក់ : ☐សាច់ប្រាក់ ☐មូលប្បទានប័ត្រ ☐ផ្សេងៗ

ចំនួនទឹកប្រាក់....................................

បង់តាមបង្កាន់ដៃលេខ.................... ចុះថ្ងៃទី......./......./.......

លេខ.រស ភាគរយបង្កប់.................... ថ្ងៃទី......./......./.......

ឈ្មោះមន្ត្រីពន្ធដារ.................... ហត្ថលេខា ....................

## Details on the Tax on Salary on Resident Employees :

| No. | Name of Employee | Nationality | Function | Salary to be Paid | Spouse | Minor Children | Allowance | Salary Tax Calculation Base | Tax Rate | Tax on Salary | Remarks |
|---|---|---|---|---|---|---|---|---|---|---|---|
| | A | B | C | D | E | F | G = ( E + F ) x 75,000 | H = D - G | I | J | K |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

Calculation Method of Tax on Salary :

If : the Salary Tax Calculation Base (H) is from 0 Riel to 800,000 Riel, it is taxed at 0%

- the Salary Tax Calculation Base (H) is from 800,001 Riel to 1,250,000 Riel, it is taxed at 5% and the method for calculation is : [ Salary Tax Calculation Base (H) x 5% ] – 40,000
- the Salary Tax Calculation Base (H) is from 1,250,001 Riel to 8,500,000 Riel, it is taxed at 10% and the method for calculation is : [ Salary Tax Calculation Base (H) x 10% ] – 102,500
- the Salary Tax Calculation Base (H) is from 8,500,001 Riel to 1,250,000 Riel, it is taxed at 15% and the method for calculation is : [ Salary Tax Calculation Base (H) x 15% ] – 527,500
- the Salary Tax Calculation Base (H) is from 12,500,001 Riel and over, it is taxed at 20% and the method for calculation is : [ Salary Tax Calculation Base (H) x 20% ] – 1,152,500

## Details on the Tax on Salary on Non-Resident Employees and Tax on Salary on Fringe Benefit :

| No. | Name of Employee | Nationality | Function | Salary to be Paid/Fringe Benefit | Tax Rate 20% | Tax on Salary | Remarks |
|---|---|---|---|---|---|---|---|
| | A | B | C | D | E | F = D x E | G |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

Notes : Please use separate sheets if the space is insufficient.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០២ សហវ.

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០១៥

## សេចក្តីណែនាំ
## ស្តីពី
## ការអនុវត្តការគណនាពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម

អនុលោមតាមបទប្បញ្ញត្តិនៃជំពូកទី២ នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស លេខ ១១៧៣ សហវ.ពដ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឱ្យមានសង្គតិភាពក្នុងការអនុវត្តការគណនាពន្ធលើប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភដូចខាងក្រោម ដែលនិយោជិត កម្មករ កម្មការិនី នៅរោងចក្រ ទទួលបានពីការបំពេញការងារ មិនត្រូវបានគិតបញ្ចូលក្នុងមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស និងមិនមែនជាកម្មវត្ថុនៃពន្ធលើអត្ថប្រយោជន៍បន្ថែមទេ៖

១. សោហ៊ុយធ្វើដំណើរពីកន្លែងស្នាក់នៅទៅទីកន្លែងធ្វើការ ឬរោងចក្រ និងពីកន្លែងធ្វើការ ឬរោងចក្រទៅកន្លែងស្នាក់នៅ និងការឧបត្ថម្ភថ្លៃស្នាក់នៅ ឬការផ្តល់កន្លែងស្នាក់នៅក្នុងបរិវេណរោងចក្រ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ការងារ
២. ប្រាក់រង្វាន់ដែលផ្តល់ឱ្យនិយោជិត កម្មករ កម្មការិនី ទាំងអស់ដោយគ្មានបែងចែកតាមតួនាទី ឬមុខងារ រួមទាំងប្រាក់ថែមម៉ោង។
៣. ម្ហូបនិងទីបែទ្យ សម្ភារៈ សម្លៀកបំពាក់ការងារ ក្នុងកម្រិតដែលបានបញ្ញត្តិក្នុងច្បាប់។
៤. ប្រាក់ឧបត្ថម្ភ ដែលផ្តល់ឱ្យដល់ និយោជិត កម្មករ កម្មការិនី គ្រប់គ្នាដោយគ្មានការបែងចែកតាមតួនាទី ឬមុខងារ។
៥. ប្រាក់ឧបត្ថម្ភ ដែលមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ការងារ។
៦. ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ឬប្រាក់បំណាច់នៃការបញ្ឈប់ពីការងារ ក្នុងកម្រិតដែលបានបញ្ញត្តិក្នុងច្បាប់ការងារ។

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រី
បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- ឯកសារកាលប្បវត្តិ

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_admin@yahoo.com